[1] នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-2012, 15:25
CMS/CFO: Uch Arun

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ : សាធារណៈ/Public
ឋានៈនៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

# បណ្ដឹងសាទុក្ខតាមៗ ជំទាស់ទៅនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម **និល ណុន** ជាប្រធាន | អៀង ធីរិទ្ធ |
| Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | **មេធាវីការពារក្ដី៖** |
| | ចៅក្រម **យ៉ា សុខន** | ផាត់ ពៅសៀង |
| | ចៅក្រមJean-Marc LAVERGNE | Diana ELLIS |
| | ចៅក្រម **យូ ឧត្តរា** | |
| | **សហមេធាវីនាំមុខតំណាងដើមបណ្ដឹង** | |

**រដ្ឋប្បវេណី:**

**ពេជ អង្គ**

Elisabeth SIMONNEAU FORT

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨២ (៦), ១០៤, ១០៥, ១០៦ (២) និង១០៧ នៃវិធានផ្ទៃក្នុង[2] សហព្រះរាជអាជ្ញាដាក់បណ្តឹងសាទុក្ខភ្លាមៗ ("បណ្តឹងសាទុក្ខ") ទៅអង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") ជំទាស់ទៅនឹង *សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១* ("សេចក្តីសម្រេចដែលរងការជំទាស់")[3]។

2. ដោយផ្អែកលើសម្អាងហេតុខាងក្រោមនេះ សហព្រះរាជអាជ្ញាយល់ឃើញថា (១) បណ្តឹងសាទុក្ខអាចទទួលយកបាន (២) សេចក្តីសម្រេចដែលរងការជំទាស់ បំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញនៃបណ្តឹងសាទុក្ខ ដោយសារសេចក្តីសម្រេចនេះមានកំហុសអង្គច្បាប់ កំហុសអង្គហេតុ និងកំហុសជាក់ស្តែងមួយចំនួនទៀត ពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង (៣) សេចក្តីសម្រេចដែលរងការជំទាស់គួរត្រូវទុកជាមោឃៈ នៅត្រង់ផ្នែកដែលអង្គជំនុំជម្រះសាលាដំបូង ដកសមត្ថកិច្ចរបស់ខ្លួនចេញ ក្នុងការបង្គាប់ឲ្យបន្តការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយមានលក្ខខណ្ឌសមស្របតាមផ្លូវច្បាប់ និង (៤) សេចក្តីសម្រេចដែលរងការជំទាស់ត្រូវតែកែប្រែ ដោយតម្រូវឲ្យជនជាប់ចោទ អនុវត្តតាមលក្ខខណ្ឌជាក់លាក់ តាមរយៈអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភ ដើម្បីផ្តល់ការគាំពារឲ្យបានសមស្របរវាងសិទ្ធិការពារដោយច្បាប់ និងផលប្រយោជន៍តាមផ្លូវច្បាប់ ពាក់ព័ន្ធនឹងការដោះលែងជនជាប់ចោទរូបនេះចេញពីមន្ទីរឃុំឃាំង។

3. ស្របពេលជាមួយនឹងការដាក់បណ្តឹងសាទុក្ខនេះ សហព្រះរាជអាជ្ញាបានដាក់៖
   (ក) សំណើសុំផ្អាកការដោះលែងទៅកាន់ប្រធានអង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") ដូចមានចែងក្នុងវិធាន ៨២ (៦) នៃវិធានផ្ទៃក្នុង និង
   (ខ) សំណើទៅកាន់អង្គជំនុំជម្រះតុលាការកំពូលឲ្យពន្យារពេលដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែម ក្នុងរយៈពេល៧ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីសេចក្តីសម្រេចដែលរងការជំទាស់។

## II. ទឡ្ហីករណ៍

### ក. បណ្តឹងសាទុក្ខអាចទទួលយកបាន

4. បណ្តឹងសាទុក្ខឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវសម្រាប់ការទទួលយក ដូចដែលបានចែងក្នុងវិធាន១០៤ វិធាន១០៥ និងវិធាន១០៧ នៃវិធានផ្ទៃក្នុង ជាពិសេស ៖

(ក) វិធាន១០៤(៤)(ក)នៃវិធានផ្ទៃក្នុង ចែងអំពីសិទ្ធិប្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចដែលមាន**<u>អានុភាព</u>**បញ្ចប់កិច្ចដំណើរការនីតិវិធី។ ការណ៍នេះរួមបញ្ចូលសេចក្តីសម្រេចដែលបង្គាប់ឲ្យផ្អាកដំណើរការនីតិវិធីគ្មានរយៈពេលកំណត់ ពីព្រោះ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ផលវិបាកនៃការផ្អាកដំណើរការនីតិវិធី គឺមានទម្ងន់គ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថាសេចក្តីសម្រេចស្តីពីការផ្អាកដំណើរការនេះ ត្រូវតែជាសេចក្តីសម្រេចដែលត្រូវប្តឹងសាទុក្ខបាន[4]។ ដោយអនុវត្តតាមយុត្តិសាស្ត្ររបស់តុលាការកំពូល សេចក្តីសម្រេចដែលរងការជំទាស់ នឹងបញ្ចប់កិច្ចដំណើរការនីតិវិធី ប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ("ជនជាប់ចោទ") ទោះបីជាមានការសង្ឃឹមការចាប់ផ្តើមសវនាការវិញមានតិចតួចយ៉ាងណាក៏ដោយ ក្នុងស្ថានភាពដែលមានការផ្លាស់ប្តូរលក្ខខណ្ឌនៃការព្យាបាលផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទ។

(ខ) វិធាន១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង ចែងអំពីសិទ្ធិប្តឹងសាទុក្ខភ្លាមៗ ជំទាស់នឹងសេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមវិធាន៨២។ សេចក្តីសម្រេចដែលរងការជំទាស់ បង្គាប់ឲ្យដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ដូច្នេះ នេះជាសេចក្តីសម្រេច អនុលោមតាមវិធាន៨២។

(គ) វិធាន១០៥(២) នៃវិធានផ្ទៃក្នុង តម្រូវថា បណ្តឹងសាទុក្ខភ្លាមៗត្រូវបញ្ជាក់ពីមូលដ្ឋានគាំទ្របណ្តឹងសាទុក្ខ និងទឡ្ហីករណ៍នានា។ វិធាននេះចែងថា មូលដ្ឋាននីមួយៗនៃបណ្តឹងសាទុក្ខត្រូវ៖ ក) បញ្ជាក់អំពីកំហុសអង្គច្បាប់ដែលចោទប្រកាន់ និងត្រូវបង្ហាញថា កំហុសនេះបណ្តាលឲ្យសេចក្តីសម្រេចមានមោឃៈភាព ឬ ខ) បញ្ជាក់អំពីកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ ឬ គ) ត្រូវបញ្ជាក់ពីកំហុសអង្គហេតុ និងបង្ហាញអំពីរបៀបដែលកំហុសអង្គហេតុ នាំឲ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ មូលដ្ឋាននៃបណ្តឹងសាទុក្ខ ដែលមាននៅខាងក្រោម បង្ហាញអំពីកំហុសអង្គច្បាប់ ដែលនាំឲ្យមោឃៈសេចក្តីសម្រេចដែលរងការជំទាស់ ហើយកំហុសអង្គហេតុ ដែលនាំឲ្យមានភាពមិនយុត្តិធម៌ ឬជាជម្រើសផ្សេង ជាកំហុសឆ្គងមួយ ក្នុងការ

អនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបណ្ដាលឲ្យប៉ះពាល់ដល់សិទ្ធិរបស់សហព្រះរាជអាជ្ញា។

(ឃ) បណ្ដឹងសាទុក្ខនេះត្រូវបានដាក់ជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេល២៤ ម៉ោង បន្ទាប់ពីមានការជូនដំណឹងស្ដីអំពីសេចក្ដីសម្រេចដែលរងការជំទាស់ ដោយអនុលោមតាមវិធាន១០៦(២) និង១០៧(៣) នៃវិធានផ្ទៃក្នុង។

## *ខ. បណ្ដឹងសាទុក្ខបំពេញតាមបទដ្ឋានសម្រាប់ការពិនិត្យឡើងវិញនៃបណ្ដឹងសាទុក្ខ*

### *(i) អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយផ្អាកយុត្តាធិការទាំងស្រុងទៅលើជនជាប់ចោទ ឬក៏ច្រានចោលយុត្តាធិការរបស់ខ្លួន*

5. កថាខណ្ឌទី៣៣ នៃសេចក្ដីសម្រេចរងការជំទាស់ ដែលរកមិនឃើញនូវមូលដ្ឋានខាងផ្លូវច្បាប់ ដើម្បីឃុំខ្លួនជនជាប់ចោទ និងផ្អាកកិច្ចដំណើរការនីតិវិធី - ដែលតាមគោលជំហររបស់សហព្រះរាជអាជ្ញាយល់ព្រមឲ្យធ្វើដូច្នេះ[5] - អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "វាហាក់ដូចជាមានកង្វះខាតនូវមូលដ្ឋានផ្លូវច្បាប់យ៉ាងច្បាស់ក្រឡែតក្នុងការដាក់លក្ខខណ្ឌផ្សេងៗ ឬទម្រង់ផ្សេងទៀតនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទនៅពេលមានការដោះលែង"[6]។ សំអាងហេតុនេះពឹងផ្អែកលើរបបគំហើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "យុត្តាធិការរបស់ខ្លួនលើជនជាប់ចោទត្រូវបានព្យួរ"[7][8] និងថាខ្លួន "មិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនជាបន្តទៀតឡើយ"[9] លើ "ជនជាប់ចោទដែលប្រឈមមុខនឹងការគ្មានសង្ឃឹមសមហេតុផលថា នឹងត្រូវបានយកមកកាត់សេចក្ដី [និង] ជាជនដែលត្រូវបានដោះលែងនោះ"[10]។

6. ដោយការព្យួរយុត្តាធិការរបស់ខ្លួនទាំងស្រុង ឬការដកខ្លួនចេញយ៉ាងមានប្រសិទ្ធភាពពីយុត្តាធិការលើជនជាប់ចោទនៅក្នុងកាលៈទេសៈនាពេលនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់ ដូចជាការធ្វើឲ្យគ្មានសុពលភាពចំពោះសេចក្ដីសម្រេចដែលរងការជំទាស់ ដោយសារមូលហេតុផ្សេងៗដូចខាងក្រោម៖

   (ក) សេចក្ដីសម្រេចដែលរងការជំទាស់នេះ ងាកចេញពីច្បាប់ អ.វ.ត.ក និងគោលការណ៍ជាមូលដ្ឋាននៃច្បាប់កម្ពុជា ដោយមិនបានផ្ដល់នូវមូលដ្ឋានច្បាប់សម្រាប់តុលាការមួយ ដើម្បីដកខ្លួនចេញពីយុត្តាធិការដោយស្ម័គ្រចិត្ត ក្នុងករណីដែលបណ្ដឹងអាជ្ញាមួយមិនត្រូវបានបញ្ចប់ដោយច្បាប់[11]។

(ខ) សេចក្តីសម្រេចដែលរងការជំទាស់ អនុវត្តដោយមានកំហុសអំពីការរកឃើញរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICC ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* ទាក់ទងនឹងភាពមិនអាចធ្វើបានចំពោះការឃុំឃាំងក្នុងករណីនៃ "ការផ្អាកដំណើរការនីតិវិធីដែលមានមិនអាចត្រឡប់ក្រោយបាន និងជាអចិន្ត្រៃយ៍"[12] ដើម្បីកុំឲ្យមានការអនុវត្តនូវវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទអៀង សារី[13]។ ក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ច្បាប់ករណីរបស់តុលាការ ICC គួរបានតម្រូវឲ្យមានរបបគំហើញខាងអង្គហេតុពីមុនណាមួយ ធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងដែលតាមពាក្យពេចន៍របស់អង្គជំនុំជម្រះតុលាការកំពូល ថាជនជាប់ចោទ"គ្មានសម្បទាជាអចិន្ត្រៃយ៍"[14]។ អង្គជំនុំជម្រះសាលាដំបូងមិនបានរកឃើញអ្វីមួយដូច្នេះទេក្នុងករណីនេះ។ តាមពិត អង្គជំនុំជម្រះសាលាដំបូងបានដាក់*ការផ្អាកដែលអាចត្រឡប់ក្រោយបាន និងមិនមែនជាអចិន្ត្រៃយ៍*" តាមរយៈការទទួលយកលទ្ធភាពនៃការធ្វើឲ្យប្រសើរឡើងវិញតាមការព្យាបាលខាងវេជ្ជសាស្ត្រដែលមានលក្ខណៈប្រសើរជាងមុន[15]ហើយនិងលទ្ធភាពនៃការបន្តសវនាការឡើងវិញ[16]។ ក្នុងបរិបទនេះ ការអនុវត្តឲ្យបានត្រឹមត្រូវនូវការសាងល្បងចំពោះករណីរឿងក្តី *Lubanga* តម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងត្រូវសួរថាតើ "លក្ខខណ្ឌសម្រាប់ការឃុំខ្លួនជាបន្តបានបំពេញដែរ ឬទេ" និងប្រសិនបើមិនបានបំពេញ "ត្រូវកំណត់ថាតើ ក្នុងកាលៈទេសជាក់លាក់នៃករណីដូច្នេះ *ការដោះលែង គួរឬមិនគួរមានលក្ខខណ្ឌ [...]*"[17]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅក្នុងការអនុវត្តផ្នែកដំបូងនៃការសាកល្បងនៅក្នុងរឿងក្តី *Lubanga* ដោយពុំបានពិចារណាពីចំណុចទីពីរដែលរំពឹងពីការអនុវត្តនូវលក្ខខណ្ឌដែលគេអាចនឹកដល់លក្ខខណ្ឌចំពោះជនជាប់ចោទណាម្នាក់ ដែលត្រូវដោះលែងពីការឃុំឃាំង។

(គ) សេចក្តីសម្រេចដែលរងការជំទាស់ បានដាក់ជនជាប់ចោទក្នុងគោលជំហរដែលគេមិនអាចទទួលបានអំពីភាពមិនប្រាកដប្រជាខាងផ្លូវច្បាប់ ដែលជនជាប់ចោទរូបនេះ ត្រូវបានចោទប្រកាន់យ៉ាងត្រឹមត្រូវ និងត្រូវបាននាំខ្លួនមកកាត់សេចក្តីចំពោះបទល្មើសឧក្រិដ្ឋដ៏សែនឃោរឃៅ[18] ប៉ុន្តែឥឡូវនេះ គាត់ត្រូវបានដាក់ឲ្យស្ថិតនៅពីលើយ៉ាងក្អេងក្អាងហួសពីយុត្តាធិការបឋម និងការការពាររបស់តុលាការដែលបានព្យួរសវនាការរបស់គាត់ ហើយគាត់នឹង

ត្រូវស្ថិតក្នុងស្ថានភាពដូច្នេះ ដោយពុំមានការត្រួតពិនិត្យណាមួយ ទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ។

### *(ii) អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់ តាមរយៈការមិនអនុវត្ត ការច្រានចោល ឬការខកខានក្នុងការពិចារណាពីមូលដ្ឋានច្បាប់ដែលមានស្រាប់សម្រាប់ការបន្តការត្រួតពិត្យតាមផ្លូវតុលាការលើជនជាប់ចោទ ដោយមានលក្ខខណ្ឌ*

*(ក) អង្គជំនុំជម្រះសាលាដំបូងគួរបានពិចារណា និងអនុវត្តមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា*

7. ក្នុងកថាខណ្ឌទី៣២ នៃសេចក្ដីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានយោងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[19] ដែលអះអាងថា ការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទជាបន្តនៅក្នុងដំណាក់កាលជំនុំជម្រះ គឺអាចធ្វើបាន ដោយអនុលោមតាមមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[20]។ ការសម្រេចនេះអនុវត្តបានយ៉ាងច្បាស់ និងដាច់មុខចំពោះជនជាប់ចោទ *ដែលមិនជាប់ឃុំ*៖

> *ច្បាស់ណាស់ថា តាមមាត្រា២២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការត្រួតពិនិត្យតាមផ្លូវតុលាការមានប្រសិទ្ធភាពក្នុងការដាក់ជនជាប់ចោទ*ឱ្យមានសេរីភាពដែល*ស្ថិតក្រោមលក្ខខណ្ឌមួយ ឬច្រើនដែលអាចរាប់បញ្ចូលទាំងការដាក់កំហិតដាក់លាក់ណាមួយទៅលើសេរីភាព* តែវាមិនមែនជាការជាប់ពន្ធនាគារទេ[21]។

យ៉ាងណាក៏ដោយ ត្រង់កថាខណ្ឌទី៣៣ នៃសេចក្ដីសម្រេចរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងមិនស្របទៅនឹងការយល់ឃើញនេះទេ ដោយមិនធ្វើការពិចារណា ឬមិនអនុវត្តមាត្រា២២៣ ថាជា "មានមូលដ្ឋានច្បាប់ច្បាស់លាស់ដើម្បីដាក់លក្ខខណ្ឌ ឬទម្រង់ផ្សេងទៀតនៃការដាក់ក្រោមការពិនិត្យតាមផ្លូវតុលាការ"[22] ទៅលើជនជាប់ចោទ អៀង ធីរិទ្ធ "នៅពេលដោះលែង"[23]។ សហព្រះរាជអាជ្ញាជូនសេចក្ដីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានខុសឆ្គងនៅក្នុងផ្នែកច្បាប់ ដោយការសន្និដ្ឋានថា ដោយសារអង្គហេតុដែលថាការឃុំខ្លួន លែងធ្វើបានតទៅទៀតហើយៗ ពុំមានវិធានការចាប់បង្ខំផ្សេងទៀតណាមួយដែលស្រាលជាងនេះ អាចត្រូវពិចារណា ឬចេញបង្គាប់បានទៀតឡើយ។ ការខកខានរបស់អង្គជំនុំជម្រះក្នុងការអនុវត្តចំណុចច្បាប់មួយដែលអាចអនុវត្តបានយ៉ាងចំៗ ដែលបានបង្កើតឡើងដោយតុលាការថ្នាក់ខ្ពស់ជាងនោះ បានធ្វើឱ្យសេចក្ដីសម្រេចរងការជំទាស់នេះ មិនមានសុពលភាព។

### *(ខ) អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការបដិសេធ វិធាន៦៥ និង ៨២ នៃវិធានផ្ទៃក្នុង ថាមិនអាចអនុវត្តបាន*

8. ត្រង់កថាខណ្ឌទី៣៣នៃសេចក្តីសម្រេចរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិធាន ៦៥ និង ៨២ នៃវិធានផ្ទៃក្នុង មិនអាចផ្តល់នូវមូលដ្ឋានផ្លូវច្បាប់សម្រាប់ការដាក់វិធានការចាប់បង្ខំទៅលើជនជាប់ចោទណាម្នាក់ដែលមិនប្រឈមនឹងលទ្ធភាពសមហេតុសមផល ក្នុងការទទួលការជំនុំជម្រះក្តីបាន[24]។ អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានបកស្រាយ វិធាន៦៥ និង ៨២ ដើម្បីអនុញ្ញាតឲ្យមានវិធានការតឹងតែង ជាជម្រើសផ្សេងទៀតជំនួសឲ្យការឃុំខ្លួន[25]។ អង្គជំនុំជម្រះសាលាដំបូងខុសឆ្គងនៅក្នុងការបដិសេធពីភាពអាចអនុវត្តបាននូវវិធាន៦៥ និង ៨២ នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។ អង្គហេតុដែលថាការឃុំខ្លួនលែងជាចម្លើយតាមផ្លូវច្បាប់ដ៏ សមស្របទៀតហើយចំពោះស្ថានភាពរបស់ អៀង ធីរិទ្ធ មិននាំឲ្យមានការសន្និដ្ឋានជាស្វ័យប្រវត្តិ ដែលថាពុំមានវិធានការជាជម្រើសផ្សេងទៀតដែលអាចត្រូវពិចារណានោះទេ។ “ដោយហេតុថា តុលាការជំនុំជម្រះគឺមានសិទ្ធិមិនអាចប្រកែកបានក្នុងការសម្រេចពីការឃុំខ្លួន តាមតក្កវិទ្យា ការទាញសេចក្តីសន្និដ្ឋានគឺផ្តល់អំណាច ក្នុងការអនុវត្តវិធានការតឹងរឹងតិចតួច”[26]។ ការខុសឆ្គងផ្នែកអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង បណ្តាលឲ្យមានការខកខានដែលខ្លួនត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យបានត្រឹមត្រូវ ដោយត្រូវធ្វើការពិចារណាឲ្យបានអស់ពីលទ្ធភាពនូវវិធានការជាជម្រើសផ្សេងៗ ហើយត្រូវធ្វើការថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទ និងផលប្រយោជន៍ដែលត្រូវប្រឈម រួមទាំងការចាំបាច់ស្តីពីការធានានូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងការការពារជនរងគ្រោះ និងសាក្សីនានាផង។

### *(គ) អង្គជំនុំជម្រះសាលាដំបូង គួរតែបានពិចារណាពី ទ្រឹស្តីនៃអំណាចដែលភ្ជាប់មកជាមួយ*

9. ទ្រឹស្តីស្តីពីអំណាចដែលភ្ជាប់មកជាមួយអនុញ្ញាតឲ្យអង្គជំនុំជម្រះ “កំណត់បញ្ហាផ្លូវច្បាប់បន្ទាប់បន្សំដែលធ្វើឲ្យមានផលវិបាកផ្ទាល់នៃនីតិវិធីដែលអង្គជំនុំជម្រះត្រូវតែមានសម្អាងហេតុ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួនជាចំបង”[27]។ យុត្តាធិការលើបញ្ហាបន្ទាប់បន្សំទាំងនេះ ត្រូវបានគិតថាចាំបាច់ដើម្បី “ធានាឲ្យមានរដ្ឋបាលតុលាការមួយល្អ និងត្រឹមត្រូវ”[28]។ ទ្រឹស្តីនេះពឹងផ្អែកយ៉ាងសំខាន់លើតុលាការអន្តរជាតិនានា ក្នុងការអនុវត្តនូវយុត្តាធិការនៅក្នុងផ្នែកដែលពុំមានរៀបរាប់ជាក់លាក់ដោយលក្ខន្តិកៈ និងច្បាប់ពាក់ព័ន្ធ[29]។ ការប្រើប្រាស់ទ្រឹស្តីនេះ បានក្លាយទៅជាការទទួលយកបានដ៏ទូលំទូលាយ ដែលវា

បានវិវត្តចូលទៅក្នុង "វិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិ"[30]។ ពិតមែនហើយ ភាពអាចអនុវត្តបាននៃទ្រឹស្តីស្តីពីអំណាចដែលភ្ជាប់មកជាមួយស្រាប់នេះ ចំពោះករណីនានានៅចំពោះមុខ អវតក ធ្លាប់ត្រូវបានទទួលស្គាល់ និងអនុវត្តនៅក្នុងសេចក្តីសម្រេចជាច្រើនរបស់អង្គបុរេជំនុំជម្រះ[31]។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អំណាចដែលភ្ជាប់មកជាមួយស្រាប់របស់អង្គជំនុំជម្រះសាលាដំបូងបានលាតសន្ធឹងរហូតទៅដល់អំណាចក្នុងការដាក់លក្ខខណ្ឌចាំបាច់ និងដែលមានសមមាត្រពីការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទណាមួយ ដែលសវនាការរបស់ខ្លួនត្រូវបានផ្អាក ជាពិសេសតាមបញ្ហាអង្គហេតុ កាលណាអង្គជំនុំជម្រះព្រមទទួលយកថា លទ្ធភាព (ទោះជាតិចតួចក៏ដោយ) នៃការធ្វើសវនាការអាចបន្តឡើងវិញបាន។ ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌណាក៏ដោយដែលបានដាក់កំហិតទៅលើសិទ្ធិមនុស្សដែលគេបានទទួលស្គាល់ជាអន្តរជាតិនោះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះត្រូវតែធ្វើឲ្យត្រូវទៅតាមលក្ខខណ្ឌ បែបដូច្នោះ ដែលនាំឲ្យមាន *ការកម្រិតដែលមានយុត្តិកម្ម* ទៅលើសិទ្ធិទាំងនោះ។

*(iii) អង្គជំនុំជម្រះសាលាដំបូង ខុសឆ្គងនៅក្នុងផ្នែកច្បាប់ ដោយបង្គាប់ឲ្យមានការដោះលែងជនជាប់ចោទនៅពេលមានលក្ខខណ្ឌដែលមានយុត្តិកម្មលើការត្រួតពិនិត្យតាមផ្លូវតុលាការ*

10. ពីមុន សហព្រះរាជអាជ្ញាធ្លាប់បានជូនសេចក្តីសន្និដ្ឋានថា គ្មានមូលដ្ឋានក្នុងការបន្តការឃុំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ តទៅទៀតហើយ[32]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា អៀង ធីរិទ្ធ គួរត្រូវបន្តនៅក្រោមរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការតទៅទៀត ហើយត្រូវអនុញ្ញាតឲ្យមានការដោះលែងជាបណ្តោះអាសន្ន នៅក្រោមលក្ខខណ្ឌចំនួនប្រាំមួយដែលអង្គជំនុំជម្រះសាលាដំបូង បង្គាប់៖ (១) ស្នាក់នៅក្នុងលំនៅដ្ឋានជាក់លាក់មួយដែលសហមេធាវីការពារក្តីរបស់គាត់ត្រូវប្រាប់ពីអាសយដ្ឋាន, (២) ឲ្យបង្ហាញខ្លួនមួយសប្តាហ៍ម្តងដើម្បីឲ្យអាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីផ្លូវការ ដែលចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង ត្រួតពិនិត្យពីសុវត្ថិភាព (៣) ឲ្យគាត់ប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ, (៤) កុំទាក់ទង ដោយត្រង់ៗក្តី ឬ ដោយប្រយោលក្តី នឹងសហជនជាប់ចោទដទៃទៀត (លើកលែងតែស្វាមីរបស់គាត់ គឺ អៀង សារី), (៥) កុំទាក់ទង ដោយត្រង់ៗក្តី ឬ ដោយប្រយោលក្តី នឹងសាក្សី អ្នកជំនាញ ឬ ជនរងគ្រោះ រូបណាក៏ដោយដែលត្រូវបានស្នើដោយអង្គជំនុំជម្រះសាលាដំបូងឲ្យចូលមកដើម្បីស្តាប់ចម្លើយ ហើយមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ហើយនិង (៦) ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រប្រាំមួយខែម្តងដោយអ្នកអនុវត្តផ្នែកវេជ្ជសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់តាំង[33]។

11. បើសិនបើការឃុំខ្លួនបន្តនៃជនជាប់ចោទត្រូវបានសំរេចឲ្យធ្វើនោះ មូលដ្ឋានច្បាប់ដែលមានលក្ខណៈចាប់បង្ខំនៅក្នុងយុត្តិសាស្ត្រ និងទម្លាប់អនុវត្តជាអន្តរជាតិអាចយកមកធ្វើការពិចារណាដើម្បីដាក់លក្ខខណ្ឌកំរិតនានា ចំពោះការដោះលែងជនជាប់ចោទណាម្នាក់ជាបណ្តោះអាសន្ន[34]។ លក្ខខណ្ឌទាំងនោះគឺជាលក្ខខណ្ឌដែលតុលាការអន្តរជាតិនានាធ្លាប់បានអនុវត្តរួចហើយ នៅក្នុងករណីរឿងក្តីស្រដៀងគ្នានេះហើយនៅក្នុងករណីខ្លះ លក្ខខណ្ឌទាំងនោះមានលក្ខណៈកម្រិតខ្លាំងជាងលក្ខណ្ឌនានាដែលបានបានស្នើឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងពេលសវនាការដោយផ្ទាល់មាត់ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២[35]។

12. ឧទាហរណ៍ដូចជា អង្គជំនុំជម្រះនៃតុលាការ ICTY បានបង្គាប់ឲ្យជនជាប់ចោទ Talić ដែលជម្ងឺរបស់គាត់ស្ថិតនៅក្នុងតំណាក់កាលចុងក្រោយ មិនអោយមកប្រឈមមុខនឹងការតំណើរការកាត់ក្តីឡើងវិញប៉ុន្តែអោយស្នាក់នៅ និង ស្ថិតនៅក្នុងអាស័យដ្ឋានជាលាក់គ្រប់ពេលមួយនៅក្នុងទីក្រុងប៊ែលក្រាដដែលកំណត់ដោយតុលាការលើកលែងតែក្នុងករណីដែលចាំបាច់ក្នុងការធ្វើដំណើរទៅធ្វើតេស្ត ទៅឲ្យពេទ្យពិនិត្យព្យាបាលជម្ងឺ និងវិធីព្យាបាលសុខភាព[36]។ តុលាការICTY ក៏បានបង្គាប់ឲ្យជនជាប់ចោទ Simatović រាយការណ៍ជារៀងរាល់ថ្ងៃដល់នគរបាលក្នុងទីក្រុងបែលហ្គ្រាដនៅស្ថានីយ៍ប៉ូលីសមូលដ្ឋានមួយដែលកំណត់ដោយក្រសួងយុត្តិធម៌[37]។ ជនជាប់ចោទStanišićត្រូវបានបង្គាប់ឲ្យប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅឲ្យក្រសួងយុត្តិធម៌[38]លើសពីនេះហាមមិនឲ្យ ធ្វើការទំនាក់ទំនងណាមួយជាមួយជនជាប់ចោទផ្សេងទៀតនៅក្នុងករណីរឿងក្តីនេះ[39] និង មានទំនាក់ទំងនជាមួយជនរងគ្រោះ ឬសាក្សីដ៏មានសក្តានិពលណាម្នាក់ទៀតឡើយ[40]។ ជាចុងក្រោយ តុលាការ ICTY បានបង្គាប់ឲ្យជនជាប់ចោទ *Đukić* ដែលមានជម្ងឺដែលមិនអាចព្យាបាលបានហើយស្ថិតនៅក្នុងតំណាក់កាលចុងក្រោយ ឲ្យរាយការណ៍អំពីការផ្លាស់ប្តូរអាសយដ្ឋាន ឲ្យធ្វើរបាយការណ៍ពេទ្យ តាមពេលកំណត់ជូនតុលាការស្តីពីស្ថានភាពជម្ងឺរបស់គាត់ ហើយត្រូវតែមកបង្ហាញខ្លួននៅពេលមានដីកាកោះហៅ[41]។

13. អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលនូវយុត្តិសាស្ត្រ និងទម្លាប់អនុវត្តរបស់អន្តរជាតិនេះដោយផ្អែកលើមូលដ្ឋាននៃភាពខុសគ្នាក្នុងអង្គហេតុទាំងនោះ”[42]។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសចទាំងអង្គហេតុ និងអង្គច្បាប់ លើចំណុចនេះដែលក្នុងនោះរួមទាំងមានការយល់ច្រលំអំពីបច្ច័យនៃសេចក្តីសម្រេចមួយចំនួនផង[43]។ គោលការណ៍ច្បាប់សំខាន់នៅក្នុងយុត្តិសាស្ត្រនេះ នៅតែមាន នេះបើយោងតាមសម្តីរបស់អង្គជំនុំជម្រះគឺ៖ “***ការដោះលែងដោយគ្មានលក្ខខណ្ឌ*** ហាក់ដូចជាត្រូវបានយកមកអនុវត្តជាករណីពិសេស***ដោយផ្អែកតែទៅលើហេតុផលខាង***

***មនុស្សធម៌*** នៅក្នុងករណីដែលជម្ងឺរបស់ជនជាប់ចោទស្ថិតក្នុងតំណាក់កាលចុងក្រោយបំផុត" (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)[44]។ នៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា សេចក្ដីសម្រេចដែលរងការតវ៉ា មិនបានរកឃើញអំពីមូលហេតុខាងមនុស្សធម៌ ឬស្ថានភាពជម្ងឺរបស់ជនជាប់ចោទស្ថិតក្នុងតំណាក់កាលចុងក្រោយបំផុត ដែលជនជាប់ចោទ អៀង ធីរិទ្ធ កំពុងតែទទួលរង ដែលអាចយកមកធ្វើជាមូលដ្ឋានខាងច្បាប់គ្រប់គ្រាន់ដើម្បីដោះលែងដោយគ្មានលក្ខខណ្ឌបង្ខំ ដែលមានលក្ខណសមរម្យឡើយ។ ផ្ទុយទៅវិញ យុត្តិសាស្ត្របានបង្ហាញឲ្យឃើញថាជនជាប់ចោទដែលមានស្ថានភាពជម្ងឺក្នុងតណាក់កាលចុងក្រោយ- ដែលទំនងជាគ្មានលទ្ធភាពក្នុងការជាសះស្បើយឡើងវិញ គឺមានសភាពធ្ងន់ធ្ងរជាងស្ថានភាពរបស់ អៀង ធីរិទ្ធ ឆ្ងាយណាស់- ហើយអ្នកទាំងនោះក៏ត្រូវទទួលការដោះលែងដោយមានលក្ខខណ្ឌដែរដូចដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា[45]។

14. សហព្រះរាជអាជ្ញាបានធ្វើសេចក្ដីសន្និដ្ឋានកន្លងមកថា ការរដាក់លក្ខខណ្ឌរឹតត្បិតលើជនជាប់ចោទដែលពុំមានសម្បទាក្នុងចូលរួមសវនាការ ហើយហេតុនេះត្រូវដោះលែងឲ្យមានសេរីភាព ដែលត្រូវមានលក្ខណៈស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងយុត្តិសាស្ត្រ និងការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ហើយក៏ដោយ ក៏ត្រូវតែបំពេញបន្ថែមទៅនឹងការធ្វើតេស្តអំពីភាពសមាមាត្រទូទៅមួយដើម្បីធ្វើការកំហិតសិទ្ធិដែលមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ[46]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវតែឆ្លើយតបអោយបាន លក្ខខណ្ឌរឹតត្បិតណាមួយថាមានលក្ខណៈ*សមស្រប ចាំបាច់* និង*សមាមាត្រ* នៅក្នុងកាលៈទេសៈទាំងនោះ។ ដូចអង្គជំនុំជម្រះសាលាដំបូង ICTY បានសម្រេចនៅក្នុងរឿងក្ដី *Talić* ៖

> *នៅពេលបកស្រាយវិធាន ៦៥ [ដែលជាវិធានសម្រាប់អនុវត្តក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ] គេត្រូវតែធ្វើការពិចារណាលើគោលការណ៍សមាមាត្រទូទៅ។ វិធានការនៅក្នុងច្បាប់អន្តរជាតិជាសាធារណៈមានលក្ខណៈសមាមាត្រតែនៅពេលដែលវិធានការនេះ (១) មានលក្ខណៈសមស្រប (២) ចាំបាច់ និងនៅពេលដែល (៣) កម្រិត និងវិសាលភាពនៃវិធានការនោះនៅតែមានទំនាក់ទំនងសមរម្យសម្រាប់ជនចាប់ចោទប៉ុណ្ណោះ។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមទៀតថា វិធានការនីតិវិធីមិនគួរមានលក្ខណៈប្រែប្រួល ឬហួសហេតុឡើយ។ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ក្នុងការអនុវត្តវិធានការស្រាលជាងវិធានការស្រាលនោះត្រូវតែអនុវត្ត*[47] ។

15. ការរឹតត្បិតស្រដៀងគ្នាចំពោះលក្ខណវិនិច្ឆ័យនៃសិទ្ធិ ត្រូវបានយកមកអនុវត្តដើម្បីរឹតត្បិតសិទ្ធិជាសារវន្ត នៅក្នុងបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ និងយុទ្ធសាស្ត្រតុលាការសំខាន់ៗដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិល[48] ប្រព័ន្ធច្បាប់ខំមិនឡូ[49] និងប្រព័ន្ធច្បាប់ចម្រុះ[50]។

16. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ក្នុងការបដិសេធមិនធ្វើការវាយតម្លៃ និងមិនថ្លឹងថ្លែងលើ "ផលប្រយោជន៍ទាំងអស់ដែលអាចប្រឈមនឹងហានិភ័យ និងមិនផ្តល់ទម្ងន់សមស្របដល់កត្តាពាក់ព័ន្ធទាំងអស់"[51] នៅពេលសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌនោះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនទាំងបំពាន ក្នុងទម្រង់មួយដែលប៉ះពាល់ដល់សិទ្ធិរបស់សហព្រះរាជអាជ្ញា។ ការពិនិត្យគតិយុត្តិលម្អិតឡើងវិញទាក់ទងនឹងលក្ខខណ្ឌនៃការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា នឹងបញ្ជាក់ពីភាពសមស្រប ភាពចាំបាច់ និងសមាមាត្រនៃសិទ្ធិជាសារវន្ត និងគោលបំណងនៃគោលនយោបាយគតិយុត្តិដែលបានចែងនៅក្នុងច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក[52]។

## (iv)អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ឬមានកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចថា លក្ខខណ្ឌនៃការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការមិនអាចអនុវត្តបាន ឬពុំមានប្រយោជន៍

17. នៅក្នុងកថាខណ្ឌ ៣៧ នៃសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា លក្ខខណ្ឌដែលមានលក្ខណៈចាប់បង្ខំ "ទំនងជាមិនអាចអនុវត្តបានតាមភាពជាក់ស្តែង ឬតាមផ្លូវគតិយុត្តិ"[53] ដោយផ្អែកលើស្ថានភាពបញ្ញាស្មារតីបច្ចុប្បន្នរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និងផ្អែកលើលទ្ធភាពដែលថា គាត់គ្មានសមត្ថភាពដោយចេតនាក្នុងការបំពានលក្ខខណ្ឌទាំងនេះ ឬក៏អាចប្រឈមទៅនឹងការដាក់ទោសដោយសារតែការបំពានទៅនឹងលក្ខខណ្ឌទាំងនេះបានទេ។ ផ្ទុយទៅវិញ នៅក្នុងផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចដែលរងការជំទាស់នេះ អង្គជំនុំជម្រះបានសម្រេចដោយធ្វើការបន្តរំឭកដល់ជនជាប់ចោទអំពីកាតព្វកិច្ចរបស់គាត់ ស្របតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង និងស្នើឲ្យគាត់បញ្ឈប់ទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក[54] ទៅវិញ។ សហព្រះរាជអាជ្ញា សូមបញ្ជាក់ដោយគោរពថា សំអាងហេតុជាមូលដ្ឋាននេះមិនអាចជួយគាំទ្រដល់ "ការរំឭក" និង "ការស្នើ" ដែលបានលើកឡើងនៅក្នុងផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចដែលរងការជំទាស់នោះទេ។

18. នៅក្នុងកថាខណ្ឌ ៣៩ នៃសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា "ការលំបាក និងការចំណាយជាក់ស្តែងក្នុងការបន្តធ្វើការវាយតម្លៃឡើងវិញតាមពេលវេលាកំណត់លើសម្បទាបញ្ញាស្មារតីរបស់ជនជាប់ចោទ"[55] រួមទាំងការសម្រេចថា ស្ថានភាពរបស់ជនជាប់ចោទមិនអាចព្យាបាលឲ្យជាបាន និងមិនអាចស្តារឡើងវិញបាន មិនផ្តល់យុត្តិកម្មដល់ការវាយតម្លៃវេជ្ជសាស្ត្រជាធម្មតាដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ឡើយ[56]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចក្តីបែបនេះ ដោយគ្មានភស្តុតាងជាមូលដ្ឋាន ដែលនាំឲ្យមានភាពមិនយុត្តិធម៌ ឬមានកំហុសយ៉ាងច្បាស់ក្រឡែតក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដែលបង្កឲ្យមានភាពលម្អៀង។ ប្រវត្តិនៃដំណើរការនីតិវិធីទាំងនេះបានបង្ហាញយ៉ាងច្បាស់ថា អ.វ.ត.ក មានលទ្ធភាពក្នុងការរៀបចំឲ្យមានការព្យាបាល និងការវាយតម្លៃវេជ្ជសាស្ត្រ តាមបទដ្ឋានអន្តរជាតិខ្ពស់បំផុត ហើយការិយាល័យរដ្ឋបាលពុំធ្លាប់បានជំទាស់ទៅនឹងការអនុវត្តវិធានការណាមួយ ដោយសារតែបញ្ហានៃការចំណាយឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃរយៈពេល ៦ ខែ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា មិនបង្កឲ្យមានការចំណាយបន្ថែមច្រើនឡើយ ពីព្រោះការវាយតម្លៃទាំងនេះអាចធ្វើឡើងដោយមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត ដោយប្រើប្រាស់កិច្ចសន្យាការងារកំពុងមានជាធរមានជាមួយនឹង អ.វ.ត.ក។

## II. សំណើ

19. អាស្រ័យដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាស្នើអង្គជំនុំជម្រះតុលាការកំពូល មេត្តា ៖

(ក) សម្រេចថា បណ្តឹងសាទុក្ខភ្លាមៗនេះ ទទួលយកបានទាំងស្រុង

(ខ) ចាត់ទុកជាមោឃៈនូវសេចក្តីសម្រេចដែលរងការជំទាស់នេះ ដោយសារអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួនគ្មានយុត្តាធិការ ដើម្បីបង្គាប់ឲ្យដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបន្ត និង

(គ) កែប្រែសេចក្តីសម្រេចដែលរងការជំទាស់នេះ ដោយបង្គាប់ឲ្យជនជាប់ចោទ(ប្រសិនបើចាំបាច់តាមរយៈអ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈដែលនឹងត្រូវតែងតាំងដោយអាជ្ញាធរជាតិ)

ដើម្បីឲ្យអនុវត្តលក្ខខណ្ឌជាក់លាក់ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ដើម្បីការពារឲ្យបានសមស្របទៅនឹងសិទ្ធិ និងផលប្រយោជន៍តាមផ្លូវច្បាប់ដែលទាក់ទងទៅការដោះលែងជនជាប់ចោទចេញពីមន្ទីរឃុំឃាំង។[57]

| ថ្ងៃទី ខែ ឆ្នាំ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ | ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |